ទីស្តីការក្រសួងយុត្តិធម៌
លេខ ៦៧៨ រវណ ភ៧/៩៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោក ប្រធានតុលាការក្រុងភ្នំពេញ**

**លោក ព្រះរាជអជ្ញាអមតុលាការក្រុងភ្នំពេញ**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** អំពីការអនុវត្តន៍សាលក្រមឬសាលដីកាស្ថាពរ ព្រមទាំងសេចក្តីសម្រេចផ្សេងៗរបស់តុលាការនិងអយ្យការ ។

**<u>យោង:</u>** -លិខិតបង្គាប់លេខ ១១៧.សរ.រវ ៩៧ ចុះថ្ងៃទី៣១-០១-១៩៩៧ របស់ក្រសួងយុត្តិធម៌ ។

-លិខិតលេខ ១១៨ រប-៩២១-៩៩ ចុះថ្ងៃទី២៩-០៣-៩៩ របស់តុលាការក្រុងភ្នំពេញ

-លិខិតលេខ ៦៥ ព្រ១៩៤០១-៩៩ ចុះថ្ងៃទី០២-០៤-៩៩ របស់អយ្យការក្រុងភ្នំពេញ

-ស្មារតីអង្គប្រជុំរបស់ក្រសួងយុត្តិធម៌ នៅថ្ងៃទី២១-០៤-៩៩ និងថ្ងៃទី១៧-០៥-៩៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកថា ការអនុវត្តន៍សាលក្រម ឬសាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ និងអយ្យការ ត្រូវតែអនុវត្តជាធម្មតាដោយពុំអាចផ្អាកជាបណ្តោះអាសន្នបានទេ ហើយអស់លោកត្រូវតែគោរពតាមច្បាប់ ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី និងសេចក្តីបង្គាប់លេខ ១១៧ សរ.រវ៩៧ ចុះថ្ងៃទី៣១-០១-៩៧ ដោយក្នុងការអនុវត្តន៍នោះលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញា ត្រូវតែសហការគ្នាអនុវត្តអោយបានល្អប្រសើរនៅក្នុងអង្គការតុលាការ ដូច្នេះអំណើះតទៅសាលក្រម ឬ ដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការនិងអយ្យការ អស់លោកត្រូវតែចាត់ការអនុវត្តតាមលិខិតណែនាំនេះអោយមានប្រសិទ្ធិភាពខ្ពស់បំផុត ។

សូមអស់លោក ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វីធុន**

<u>ចម្លងជូន</u>
-លោកប្រធានតុលាការខេត្ត-ក្រុង
-លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង
-ដើម្បីជ្រាប និង អនុវត្ត